AN & LOR
ATTORNEYS-AT-LAW
ក្រុមមេធាវី អន អេន ឡោ

ព្រឹត្តិបត្រគតិយុត្ត
សំរាប់ ខែ មេសា ឆ្នាំ ២០២១

# ច្បាប់ស្តីពីជំងឺកូវីដ-១៩ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ក្នុងអំឡុងពេលនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ជាបន្តបន្ទាប់

ការប្រកាសដាក់ឱ្យប្រើប្រាស់បន្ទាន់នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃ ជំងឺកូវីដ-១៩ និង ជំងឺឆ្លង កាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតនេះ (ហៅកាត់ថា "**ច្បាប់ស្តីពីជំងឺកូវីដ-១៩**") ត្រូវបានធ្វើឡើងនៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២១។

គួរឱ្យកត់សម្គាត់ផងដែរថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (ហៅកាត់ថា "**រាជរដ្ឋាភិបាល**") ក៏ដូចជាមន្ត្រីសុខាភិបាលជួរមុខ បានខិតខំប្រឹងប្រែងយ៉ាងសស្រាក់សស្រាំឥតឈប់ឈរក្នុងការរិះរកវិធានការ ដើម្បីទប់ស្កាត់នឹងការឆ្លងរីករាលដាលនៃជំងឺរាតត្បាតដ៏កាចសាហាវនេះនៅក្នុងសហគមន៍ ក្នុងខណៈពេលដែលមនុស្សអសីលធម៌មួយចំនួនតូចមិនបានគោរពនូវវិធានការសុខាភិបាលរបស់រដ្ឋាភិបាល ហើយបានរត់គេចចេញពីកន្លែងធ្វើចត្តាឡីស័ក ដែលជាហេតុបង្កឱ្យមានការផ្ទុះឡើងនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍នាពេលថ្មីៗនេះ។

## ១. វិសាលភាព និងគោលបំណង

ច្បាប់ស្តីពីជំងឺកូវីដ-១៩នេះចែកចេញជា ៦ ជំពូក និង ១៨ មាត្រា ដែលមានវិសាលភាពអនុវត្តនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះបង្កើតឡើងក្នុងគោលបំណងការពារសុខុមាលភាពសាធារណៈ និងអាយុជីវិត ជាពិសេស គឺដើម្បីទប់ស្កាត់ទៅនឹងការឆ្លងរាលដាលយ៉ាងឆាប់រហ័សនៃជំងឺកូវីដ-១៩ និង ជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត តាមរយៈការដាក់ចេញនូវវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងទៀត។

## ២. វិធានការទប់ស្កាត់

ច្បាប់នេះបានដាក់ចេញនូវវិធានការចំនួន ០២ (ពីរ) ដើម្បីទប់ស្កាត់នូវការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺប្រហាក់ប្រហែលគ្នានេះ៖

### ២.១. វិធានការសុខាភិបាល

រាជរដ្ឋាភិបាលមានសិទ្ធិក្នុងការដាក់ចេញនូវវិធានការសុខាភិបាលដែលចាំបាច់នានាដូចជា៖ ការធ្វើអនាម័យ ការពាក់ម៉ាស់ ការរក្សាគម្លាតសុវត្ថិភាពសង្គម ការយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ការធ្វើចត្តាឡីស័ក ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ការដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល ការធ្វើសេចក្តីប្រកាសសុខភាព និងវិធានការសុខាភិបាលផ្សេងទៀតដែលមានភាពចាំបាច់ដើម្បីឆ្លើយតប និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩។ យ៉ាងណាមិញ វិធានការសុខាភិបាលទាំងនេះ នឹងមានចែងលម្អិតបន្ថែមក្នុងអនុក្រឹត្យរបស់ក្រសួង។

### ២.២. វិធានការរដ្ឋបាល និងវិធានការផ្សេងទៀត

បន្ថែមទៅលើវិធានការសុខាភិបាលនេះ រាជរដ្ឋាភិបាលអាចដាក់ចេញជាបណ្ដោះអាសន្ននូវ វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដែលចាំបាច់ក្នុងការទប់ស្កាត់ និងឆ្លើយតបឱ្យបានទាន់ពេលវេលាទៅនឹងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ផងដែរ តាមរយៈការរឹតត្បិត ឬ ការហាមឃាត់នូវៈ

ការធ្វើដំណើរ ការជួបជុំនានា និងការប្រមូលផ្ដុំមនុស្សដែលអាចបណ្ដាលឱ្យមានការឆ្លងជំងឺកូវីដ-១៩ ការធ្វើសកម្មភាពការងារ ឬមុខរបរដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ការធ្វើពាណិជ្ជកម្មលើទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឬ ចាត់វិធានការក្នុងការបិទខ្ទប់នូវតំបន់ ឬ ទីកន្លែងមួយចំនួនដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ព្រមទាំងវិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដែលមានភាពចាំបាច់ ក្នុងការឆ្លើយតប និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

នៅក្នុងករណីដែលចាំបាច់ និងបន្ទាន់ រាជរដ្ឋាភិបាលអាចប្រគល់សិទ្ធិអំណាចទៅដល់ក្រសួង ស្ថាប័ន ឬ អាជ្ញាធរមានសមត្ថកិច្ចដើម្បីដាក់ចេញនូវវិធានការខាងលើ និងធានាដល់ការអនុវត្តវិធានការខាងលើ សំដៅទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ឱ្យបានទាន់ពេលវេលា។

## ៣. បទប្បញ្ញត្តិដែលមានជាធរមាន

រាល់លិខិតបទដ្ឋានគតិយុត្ត ឬបទប្បញ្ញត្តិដែលពាក់ព័ន្ធទៅនឹងវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដើម្បីប្រយុទ្ធប្រឆាំង និងទប់ស្កាត់នូវការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលមានមុនពេលច្បាប់នេះចូលជាធរមាន ហើយមិនផ្ទុយពីច្បាប់នេះ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស។

## ៤. ទណ្ឌកម្ម

បុគ្គលរូបណាដែលមិនគោរព ឬ បំពានទៅលើវិធានការដែលមានចែងនៅក្នុងច្បាប់នេះ ត្រូវទទួលនូវទណ្ឌកម្មដូចខាងក្រោមៈ

### ៤.១. ទណ្ឌកម្មរដ្ឋបាល

ការសម្រេចដាក់ទណ្ឌកម្មទៅលើអ្នករំលោភបំពានទៅលើវិធានការរដ្ឋបាល និងវិធានការផ្សេងទៀត គឺជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរដែលជាអ្នកទទួលខុសត្រូវដាក់ចេញនូវវិធានការរដ្ឋបាលនោះ។

ទណ្ឌកម្មរដ្ឋបាលនេះរាប់បញ្ចូលទាំងការព្យួរ ឬការដកហូតអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម ព្រមទាំងការបិទអាជីវកម្មទាំងស្រុង។ ប៉ុន្តែ ក្នុងករណីបុគ្គលណាមួយមិនពេញចិត្តលើសេចក្ដីសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលខាងលើ បុគ្គលនោះអាចដាក់ពាក្យប្ដឹងតវ៉ាទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នដែលមានសមត្ថកិច្ចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានសេចក្ដីសម្រេចពីការដាក់ទណ្ឌកម្មនោះ។

លើសពីនេះទៅទៀត ក្នុងករណីដែលបុគ្គលនោះនៅតែមិនពេញចិត្តទៅនឹងសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នដែលមានសមត្ថកិច្ចទៀត បុគ្គលនោះអាចដាក់ពាក្យបណ្ដឹងទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានសេចក្ដីសម្រេចលើបណ្ដឹងតវ៉ានោះ ។ យ៉ាងណាមិញ ការដាក់ពាក្យបណ្ដឹងតវ៉ានេះមិនមានអានុភាពផ្អាកការអនុវត្តសេចក្ដីសម្រេចស្ដីពីការដាក់ទណ្ឌកម្មខាងលើនេះឡើយ។

## ៤.២. ទណ្ឌកម្មព្រហ្មទណ្ឌ

ច្បាប់នេះមានចែងអំពីបទល្មើសចំនួន ០៦ (ប្រាំមួយ) ប្រភេទដូចខាងក្រោម៖

### ៤.២.១. បទគេចវេះពីការធ្វើចត្តាឡីស័ក ឬ គេចចេញពីកន្លែងធ្វើចត្តាឡីស័ក

ពិន័យអន្តរការណ៍ នឹងត្រូវបានដាក់ចេញទៅលើបុគ្គលទាំងឡាយណាដែលគេចវេះ ឬ គេចចេញពីកន្លែងធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលដែលធ្វើចត្តាឡីស័កដែលកំណត់ដោយក្រសួងសុខាភិបាល ឬ អាជ្ញាធរមានសមត្ថកិច្ច ដោយស្របតាមអនុក្រឹត្យ។

ប្រសិនបើជនណាដែលប្រព្រឹត្តអំពើបំពានខាងលើនេះ បណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ទៅអ្នកដទៃ ជននោះនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦ (ប្រាំមួយ) ខែ ទៅ ០៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០. ០០០.០០០ (ដប់លាន) រៀល។

### ៤.២.២. បទគេចវេះពីការព្យាបាល ឬគេចចេញពីទីកន្លែងព្យាបាល

រាល់អំពើនៃការប្រព្រឹត្ត ឬ ប៉ុនប៉ងក្នុងការប្រព្រឹត្តអំពើគេចវេះពីការតម្រូវឱ្យទទួលការព្យាបាល ឬគេចចេញពីទីកន្លែងព្យាបាលដែលកំណត់ដោយក្រសួងសុខាភិបាលនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ) ឆ្នាំ ទៅ ០៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល។

ក្នុងករណីដែលអំពើខាងលើបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ដល់អ្នកដទៃ នោះការផ្តន្ទាទោសនឹងធ្ងន់ជាងមុន ដោយត្រូវដាក់ពន្ធនាគារពី ០៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ។

### ៤.២.៣. បទចម្លងដោយចេតនានូវជំងឺកូវីដ-១៩ ដល់អ្នកដទៃ

អំពើចម្លងជំងឺកូវីដ-១៩ដោយចេតនាទៅអ្នកដទៃ មិនថាតាមមធ្យោបាយអ្វី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ។

យ៉ាងណាមិញ ការផ្តន្ទាទោសដាក់ពន្ធនាគារនេះត្រូវកើន ពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើអំពើនេះត្រូវបានធ្វើឡើងដោយមានការរៀបចំជាក្រុម ឬ អង្គការចាត់តាំង។

### ៤.២.៤. បទមិនគោរពវិធានរដ្ឋបាល

ដោយមិនគិតពីបទល្មើសព្រហ្មទណ្ឌដទៃទៀត អំពើនៃការមិនគោរពដោយចេតនានូវវិធានការរដ្ឋបាលដែលបានដាក់ចេញស្របទៅតាមច្បាប់នេះ ត្រូវទទួលរងពិន័យអន្តរការណ៍ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល។

ប្រសិនបើអំពើនេះបានបណ្តាលឱ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ទៅអ្នកដទៃ នោះជនល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦ (ប្រាំមួយ) ខែ ទៅ ០៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

លើសពីនេះ កាលបើអំពើខាងលើនេះបានបណ្តាលឱ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់

សុខមាលភាពសាធារណៈ នោះជនល្មើសនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០២ (ពីរ) ឆ្នាំ ទៅ ០៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល។

### ៤.២.៥. បទរារាំងដល់ការអនុវត្តវិធានការ

អំពើដែលរារាំង ឬបង្កជាឧបសគ្គដោយចេតនា ទៅដល់ការអនុវត្តវិធានការដែលមានចែងក្នុងច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦ (ប្រាំមួយ) ខែ ទៅ ០៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

បន្ថែមពីនេះ ក្នុងករណីដែលអំពើខាងលើធ្វើឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ ឬ ធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ នោះការផ្តន្ទាទោសនឹងកាន់តែធ្ងន់ធ្ងរ ដោយត្រូវដាក់ពន្ធនាគារពី ០២ (ពីរ) ឆ្នាំ ទៅ ០៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល។

### ៤.២.៦. ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច

មិនត្រឹមតែប្រជាពលរដ្ឋប៉ុណ្ណោះទេដែលត្រូវទទួលខុសត្រូវក្នុងការទប់ស្កាប់នូវការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ សូម្បីតែអាជ្ញាធរមានសមត្ថកិច្ចក៏ត្រូវមានទំនួលខុសត្រូវលើបញ្ហានេះផងដែរ។ ច្បាប់នេះ បានដាក់ពិន័យអាជ្ញាធរមានសមត្ថកិច្ចទាំងឡាយណាដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្ត ដោយរំលោភបំពានខុសពីគោលបំណងនៃច្បាប់នេះ ដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព បូរណភាពរូបរាងកាយ ឬ ធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ដោយឱ្យអាជ្ញាធរមានសមត្ថកិច្ចដែលល្មើសនោះទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងករណីដែលអំពើល្មើសនឹងមាត្រាណាមួយរបស់ជនបង្ក បង្កើតឱ្យមានបទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា នោះជនបង្កត្រូវទទួលខុសត្រូវទាំងចំពោះមុខច្បាប់នេះ និងច្បាប់ព្រហ្មទណ្ឌ។

## ៥. អញ្ញត្រកម្ម

ច្បាប់ស្តីពីជំងឺកូវីដ-១៩នេះក៏មានចែងអំពីការលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវ ឬ ទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ។

ជាពិសេសនោះគឺ ការលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវ ឬ ទទួលបានការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដូចមានចែងក្នុងមាត្រា៧ មាត្រា៨ មាត្រា១០ និងមាត្រា១១ ប្រសិនបើត្រូវនឹងលក្ខខណ្ឌដែលច្បាប់តម្រូវ។ ដើម្បីរួចផុតពីការទទួលខុសត្រូវ ឬទទួលបានការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ ជនល្មើស ឬក្រុមគ្រួសាររបស់ជននោះ ត្រូវផ្តល់ព័ត៌មាន ឬការសហការដល់មន្ត្រីសុខាភិបាល ឬមន្ត្រីមានសមត្ថកិច្ចដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ឱ្យបានទាន់ពេលវេលា។

យ៉ាងណាមិញ អញ្ញត្រកម្មនេះមិនអនុវត្តចំពោះបទល្មើសដែលមានចែងនៅក្នុងមាត្រា ៩ (បទចម្លងដោយចេតនានូវជំងឺកូវីដ-១៩ ដល់អ្នកដទៃ) ឡើយ។

## ៦. សេចក្តីសន្និដ្ឋាន

ច្បាប់ស្តីពីជំងឺកូវីដ-១៩ នេះគឺជាលិខិតបទដ្ឋានគតិយុត្តមួយដែលផ្តល់សិទ្ធិអំណាចជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីប្រើប្រាស់ដោយស្របច្បាប់នូវវិធានការដើម្បីទប់ស្កាត់នូវការចម្លងជំងឺកូវីដ-១៩ ជាពិសេសគឺដើម្បីឆ្លើយតបឱ្យទាន់ស្ថានការណ៍នៃព្រឹត្តការណ៍សហគមន៍ "២០ កុម្ភៈ" ដោយក្នុងនោះក៏ត្រូវអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ទាក់ទងនឹងសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋផងដែរ។ បន្ថែមពីលើនេះ វិធានការដែលមានចែងក្នុងច្បាប់ស្តីពីជំងឺកូវីដ-១៩នេះ ត្រូវបានគេជឿជាក់ថានឹងជួយកាត់បន្ថយនូវផលប៉ះពាល់ជាអវិជ្ជមាននៃជំងឺកូវីដ-១៩ទៅលើសេដ្ឋកិច្ចជាតិ សុខុមាលភាពសាធារណៈ និងជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជាទាំងមូល៕

ប្រសិនបើលោកអ្នកមានចម្ងល់ទាក់ទងនឹងព្រឹត្តិបត្រគតិយុត្តនេះ លោកអ្នកអាចធ្វើការទំនាក់ទំនងមកកាន់ក្រុមការងារយើងខ្ញុំតាមរយៈអ៊ីម៉ែល info@anlor.legal ឬធ្វើការទំនាក់ទំនងមកកាន់អ្នកជំនាញរបស់យើងខ្ញុំដូចខាងក្រោម៖



**អ្នកស្រីមេធាវី ឡោ កត្តិកា**
*នាយិកាគ្រប់គ្រង*
ទូរស័ព្ទ: (+៨៥៥) ១២ ៨៩ ៨៩ ៥៥
អ៊ីម៉ែល: kattika@anlor.legal



**លោកមេធាវី អន ប៊ុនណារិទ្ធ**
*នាយក*
ទូរស័ព្ទ: (+៨៥៥)៨៥ ៩៩ ៩៩ ៣៩
អ៊ីម៉ែល: bunnarith@anlor.legal

***ការបដិសេធន៍ទទួលខុសត្រូវ៖*** *ព្រឹត្តិបត្រគតិយុត្តនេះត្រូវបានតាក់តែងឡើងក្នុងគោលបំណងជាជំនួយស្មារតីផ្នែកច្បាប់តែប៉ុណ្ណោះ ។ ទោះស្ថិតក្នុងករណីណាក៏ដោយ ព្រឹត្តិបត្រគតិយុត្តនេះមិនត្រូវបានតាក់តែងឡើង ឬចាត់ទុកជាការផ្តល់ប្រឹក្សាផ្នែកច្បាប់ដែលលោកអ្នកអាចយកធ្វើជាអំណះអំណាង ឬជាមូលដ្ឋានច្បាប់នោះទេ។ ការផ្តល់ប្រឹក្សាផ្នែកច្បាប់គួរតែធ្វើឡើងដោយផ្អែកលើអង្គហេតុជាក់ស្តែងនីមួយៗ។ ព្រឹត្តិបត្រគតិយុត្តនេះត្រូវបានរក្សាសិទ្ធិដោយក្រុមមេធាវី អន អេន ឡោ។ ព្រឹត្តិបត្រគតិយុត្តនេះមិនគួរត្រូវបានតាក់តែងឡើងវិញ ឬ បំលែងន័យសេចក្តី ទោះក្នុងរូបភាពណា ឬដោយវិធីសាស្ត្រណា មិនថាដោយផ្នែក ឬទាំងស្រុងនោះឡើយ ប្រសិនបើគ្មានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីក្រុមមេធាវីយើងខ្ញុំជាម្ចាស់ព្រឹត្តិបត្រគតិយុត្ត។*